**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.២៤...០១៧...០០៧ ប្រ.ភ.ព.ត.ម

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឲ្យដំណើរការបឋមប្រព័ន្ធ Cambodian Shared Switch (CSS)

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាសហការជាមួយគ្រឹះស្ថានធនាគារ អេស៊ីលីដា ធនាគារស្ថាបនា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើប្រាសាក់ បានដាក់ឲ្យដំណើរការជាបឋមប្រព័ន្ធ "Cambodian Shared Switch" ដែលជាប្រព័ន្ធរួមបញ្ចូលគ្នាមួយសម្រាប់សម្រួលដល់អតិថិជនធ្វើប្រតិបត្តិការអន្តរធនាគារតាមរយៈប័ណ្ណទូទាត់លើម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល និងឆាប់រហ័ស។

គោលបំណងនៃការដាក់ឲ្យដំណើរការបឋមប្រព័ន្ធ CSS គឺដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់ កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ លើកកម្ពស់ប្រសិទ្ធភាពសេវាទូទាត់នៅកម្ពុជាឱ្យកាន់តែប្រសើរឡើង និងជំរុញប្រតិបត្តិការអន្តរធនាគារឲ្យកាន់តែទូលំទូលាយតាមរយៈការផ្តល់មធ្យោបាយធ្វើប្រតិបត្តិការបន្ថែមទៀតសម្រាប់អតិថិជន។ ម្យ៉ាងវិញទៀត ជាមួយនឹងបណ្តាញ ATM ទូលំទូលាយរបស់គ្រឹះស្ថានសមាជិក ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាធនាគារបាន ដែលនឹងអាចរួមចំណែកយ៉ាងសកម្មក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសេដ្ឋកិច្ច។ ប្រព័ន្ធ CSS ផ្តល់លទ្ធភាពដល់អតិថិជនរបស់គ្រឹះស្ថានជាសមាជិកក្នុងការធ្វើប្រតិបត្តិការទូទាត់ទំនិញនិងសេវា ដកប្រាក់ ផ្ទេរប្រាក់អន្តរធនាគារ ពិនិត្យសមតុល្យគណនី និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប តាមម៉ាស៊ីន ATM ឬ POS របស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធCSS ។

នាពេលឆាប់ៗខាងមុខ បន្ទាប់ពីការដាក់ឱ្យដំណើរការបឋមបានជោគជ័យ អតិថិជនអាចប្រើម៉ាស៊ីន ATM ឬ POS បានកាន់តែទូលំទូលាយថែមទៀត ព្រោះក្រៅពីគ្រឹះស្ថានស្ថាបនិកទាំងបីខាងលើ នៅមានគ្រឹះស្ថានធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផ្សេងទៀតបាននិងកំពុងដាក់ពាក្យសុំចូលជាសមាជិកប្រព័ន្ធ ។/

ទំនាក់ទំនង៖
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ ៖ (៨៥៥) ១២ ៣៩៣ ៦០០
អ៊ីមែល ៖ nbccommunication@nbc.org.kh/ psd@nbc.org.kh